មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI00147

# សម្ភាសន៍ជាមួយឈ្មោះ រស់ សោភឿង ភេទស្រី អាយុ៥១ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ "ប្រធានកង"

## សព្វថ្ងៃរស់នៅភូមិជើងវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ចាន់ ប្រុញ និង សោម ប៊ុនថន

០០:៤៧:៤២

២៤ទំព័រ

ប្រុញ ៖ ហ្នឹងហើយសម័យខ្មែរគ្រាមទីមួយ?

អ្នកមីងពេលអត់ទាន់ចូលសម័យខ្មែរក្រហមអ្នកមីងនៅណាវិញ?

សោភឿង ៖ ទេ! នៅសំប៉ែន ។

ប្រុញ ៖ នៅភូមិហ្នឹងដដែរ? សុំទោសអ្នកមីងឈ្មោះអីគេ?

សោភឿង ៖ ហ៊ាស ។

ប្រុញ ៖ ឈ្មោះពេញ?

សោភឿង ៖ រស់ សោភឿង ។

ប្រុញ ៖ រស់ សោភឿង?

សោភឿង ៖ ចាស ។

ប្រុញ ៖ អ្នកមីងកើតនៅឯណា? ស្រុកកំណើត?

សោភឿង ៖ ស្រុកនេះអែង!

ប្រុញ ៖ ស្រុកអ៊ី? គេហៅថាអីគេ? ភូមិអីគេ?

សោភឿង ៖ ភូមិជើងវត្ត ។

ប្រុញ ៖ ភូមិជើងវត្ត ។

សោភឿង ៖ ចាស ។

ប្រុញ ៖ ភូមិជើងវត្ត? ស្រុកជើងវត្ត?

សោភឿង ៖ ភូមិព្រះនេត្រព្រះ ។

ប្រុញ ៖ ភូមិព្រះនេត្រព្រះ?

សោភឿង ៖ ស្រុកព្រះនេត្រព្រះ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ប្រុញ ៖ ស្រុកព្រះនេត្រព្រះ?

ប៊ុនថន ៖ មីងអាយុប៉ុន្មានហើយ?

សោភឿង ៖ ខ្ញុំហ្នឹង៥១ហើយ ។

ប៊ុនថន ៖ បាទ!

ប្រុញ ៖ ៥១?

សោភឿង ៖ ចាស ។

ប្រុញ ៖ មុខរបរ?

សោភឿង ៖ ស្រែមិនធ្វើអីផង ។

ប្រុញ ៖ ចុះសម័យមុនពីឆ្នាំ៧០អីហ្នឹង អ្នកមីងស្នាក់នៅហ្នឹង ឬរស់នៅហ្នឹងដដែល?

សោភឿង ៖ ជម្លៀសទៅនៅភូមិតាប៉ែន ។

ប្រុញ ៖ ជម្លៀសឆ្នាំប៉ុន្មានដែរ?

សោភឿង ៖ ចាស ។

ប្រុញ ៖ ក្នុងសម័យអីលន់ នល់ ?

សោភឿង ៖ សម័យលន់ ណល់ នៅនេះអែង ។

ប្រុញ ៖ អូ! សម័យ លន់ លន់ នៅហ្នឹងទេ?

សោភឿង ៖ ចាស ។

ប្រុញ ៖ បាទ ។

សោភឿង ៖ កាលប៉ុល ពត បានជម្លៀស ។

ប្រុញ ៖ អូ! កាលនល់ លន់ អ្នកមីងធ្វើអីគេដែរ?

សោភឿង ៖ ខ្ញុំមិនធ្វើអី ធ្វើតែស្រែ ។

ប្រុញ ៖ អូ! ធ្វើស្រែ ហើយរៀនអីចឹងទៅ?

សោភឿង ៖ ចាស ។

ប្រុញ ៖ រៀនដល់ថ្នាក់ណាដែរ?

សោភឿង ៖ អត់បានរៀន ។

ប្រុញ ៖ អើ ពេលដែលខ្មែរក្រហមចូលមកភូមហ្នឹង គេជម្លៀសអ្នកមីងទៅណាដែរ?

សោភឿង ៖ នៅអើ ភូមិនោះតាប៉ែន ។

ប្រុញ ៖ ភូមិ? តាប៉ែន?

សោរឿង ៖ ចាស ។

ប្រុញ ៖ ភូមិតាប៉ែន? ពេលជម្លៀសទៅភូមិតាប៉ែននោះ គេឲ្យមីងធ្វើអីគេមីង?

សោរឿង ៖ ចាស ។

ប្រុញ ៖ គេឲ្យធ្វើអីគេ?

សោរឿង ៖ ភូមិតាប៉ែនហ្នឹង គេឲ្យដាំដំឡូង ។

ប្រុញ ៖ ដាំដំឡូង?

សោរឿង ៖ ដាំចម្ការ ។

ប្រុញ ៖ មានបានលើកទំនប់លើកអីនៅភូមិតាប៉ែនហ្នឹងទេ?

សោរឿង ៖ អត់បាន ។

ប្រុញ ៖ អត់បានលើកទេ?

សោរឿង ៖ ចាស ។

ប្រុញ ៖ អាយុប៉ុន្មានដែរកាលហ្នឹង?

សោរឿង ៖ ខ្ញុំហ្នឹង? ២៥ ។

ប្រុញ ៖ អាយុកាលជម្លៀសទៅហ្នឹងប្រហែល២៥?

សោរឿង ៖ ចាស ។

ប្រុញ ៖ ២៥? ហើយកាលទៅហ្នឹងមានគេធ្វើការច្រើនទេនៅភូមិតាប៉ែន?

សោរឿង ៖ ច្រើនគេធ្វើ ។

ប្រុញ ៖ ភាគច្រើនគេធ្វើហ្នឹងគេកាលណុង?

សោរឿង ៖ គេធ្វើកាប់ចម្ការខ្លះទៅ គេធ្វើដកសំណាប

ប្រុញ ៖ ចុះអី ភូមិហ្នឹងជាភូមិថ្មីសុទ្ធ? កាលដែលអត់ទាន់ទៅ?

សោរឿង ៖ ភូមិចាស់ហ្នឹង តែគេដូរគ្នា ។

ប្រុញ ៖ បាទ ។

សោរឿង ៖ ខ្ញុំពោយក្លៀងខ្ញុំមកនៅណោះ

ប្រុញ ៖ អីចឹង? មីងនៅហ្នឹងបានប៉ុន្មាន? នៅបានប៉ុន្មានខែ?

សោរឿង ៖ ចាស អើ ចូលសន្តិភាពវៀតណាម ។

ប្រុញ ៖ អើអីចឹងរស់នៅភូមិតាប៉ែនហ្នឹងរហូត?

សោរឿង ៖ កាលដែរវៀតណាមវល់វះ ចូលមកមកនៅស្រុកឯងវិញ ។

ប្រុញ ៖ ភូមិ? មីងអាចរៀបរាប់ឲ្យលំអិតក្នុងភូមិតាប៉ែនមីងធ្វើអីគេៗដូចថាក្នុងភូមិណុង?

សោរឿង ៖ ចាស ។ គេអីគេធ្វើប្រើខ្ញុំឲ្យ ខ្វះធ្វើស្រែ ខ្ញុំចល័ត ដែលខ្ញុំក្មេងនៅលីវ ។

ប្រុញ ៖ បាទ ។

សោរឿង ៖ គេឲ្យខ្ញុំគិចទៅលើកទំនប់ ។

ប្រុញ ៖ លើកទំនប់? ទំនប់អីគេ?

សោរឿង ៖ លើកទំនប់អេស្រុកភូមិត្រឡោក ។

ប្រុញ ៖ អឺភូមិត្រឡោក?

សោរឿង ៖ ចាស ។

ប្រុញ ៖ លើកទំនប់? ហើយទំនប់នេះឈ្មោះអីគេ? ទំនប់?

សោរឿង ៖ ចាស?

ប្រុញ ៖ អឺ

សោរឿង ៖ ទំនប់ភ្លឺស្រែ ។

ប្រុញ ៖ អូ៎ គេឲ្យលើភ្លឺស្រែ?

សោរឿង ៖ ចាស! ទំនប់តូចប្រព័ន្ធភ្លឺស្រែ ។

ប្រុញ ៖ ចុះអ្នកផ្សេងៗទៀត ។

សោរឿង ៖ ទំនប់ពាមរាប អានោះខ្ពស់ធំ ។

ប្រុញ ៖ ពាមរាប? ហើយអានោះគេហៅឈ្មោះអីគេ?

សោរឿង ៖ ទំនប់ត្រពាំងថ្ម ។

ប្រុញ ៖ ត្រពាំងថ្ម? អឺភូមិធំ? ហើយគេហៅខុសគ្នា

សោរឿង ៖ ចាស ។

ប្រុញ ៖ ចឹងដំបូងមីង? បាននៅភូមិប៉ែនហ្នឹងរហូតចុះម៉េចបានទៅលើកទំនប់?

សោរឿង ៖ ឲ្យគេទៅស្រែណោះ ដល់ទៅស្រែគេចល័តណាទៅប្រដោយ ដល់ចល័តទៅស្រែគេឲ្យ លើកទំនប់នេះត្រពាំងថ្ម ។

ប្រុញ ៖ បាទ! ពេលដែលអឺ?

សោរឿង ៖ គេឲ្យខ្ញុំនៅក្មេងខ្ញុំចេះទៅណោះទៅណោះ

ប្រុញ ៖ ឧទាហរណ៍អ្នកមីងធ្វើបានប៉ុន្មានខែទើបចល័ត? អត់ឲ្យទៅត្រពាំងថ្ម?ដ

សោរឿង ៖ នៅមិនបានយូរដែរ ។

ប្រុញ ៖ នៅបានប្រហែលជិត? ម៉ាឆ្នាំ?

សោរឿង ៖ ហ្នឹងហើយ ។

ប្រុញ ៖ បានដែលអត់ទេ?

សោរឿង ៖ បានជិតម៉ាឆ្នាំ ។

ប្រុញ ៖ បានប្រហែលម៉ាឆ្នាំ?

សោរឿង ៖ បានប្រហែលម៉ាឆ្នាំ គេឲ្យទៅធ្វើឯ នេះឯ ណោះ ។

ប្រុញ ៖ ទៅធ្វើការទៅធ្វើនៅឯ ត្រពាំងថ្មហ្នឹងហ្មង៉?

សោរឿង ៖ លើកទំនប់ប្រហែលបានពីរខែ ។

ប្រុញ ៖ លើកបានប្រហែលជាពីរខែទេ?

សោរឿង ៖ លើកបានតែពីរខែ ពេលនេះខ្ញុំឈឺខ្ញុំមកវិញ ។

ប្រុញ ៖ អូ៎ អីចឹងបានទៅលើកទំនប់ត្រពាំងថ្មបានតែពីរខែទេ?

សោរឿង ៖ ចា៎ស ។

ប្រុញ ៖ ហុីអូ៎! អ្នកមីងចាំទៅហ្នឹងក្នុងខែណា?

សោរឿង ៖ មិនចាំ ។

ប្រុញ ៖ ហើយគេឲ្យលើកទំនប់នេះលើកម៉េចខ្លះទៅអ្នកមីង?

សោរឿង ៖ កាប់ វាស់មែត្រគូបហើយកាប់វែកខ្លួនឯង ។

ប្រុញ ៖ កាប់វែកខ្លួនឯង?

សោរឿង ៖ កាប់វែកស្មា ។

ប្រុញ ៖ ហើយម៉ាថ្ងៃគេឲ្យកាប់វែកប៉ុន្មានគីបទៅ?

សោរឿង ៖ ម៉ាថ្ងៃម៉ាគីបលើកឲ្យរួច ។

ប្រុញ ៖ ម៉ាថ្ងៃតែមួយម៉ាម៉ែត្រគីបទេ?

សោរឿង ៖ ចា៎ស ។

ប្រុញ ៖ ចឹងអីគេផ្សេងៗវិញម៉ាម៉ែត្រគីបដែរ?

សោរឿង ៖ ដូចគ្នា ។

ប្រុញ ៖ ចឹងយើងដល់ម៉ាម៉ែត្រគីបហ្នឹងយើងធ្វើពីស្មាណាដល់ស្មាម៉ានទៅ?

សោរឿង ៖ ព្រឹកទៅលើកដល់ល្ងាច ។ បើយើងមិនរួចល្ងាច ។

ប្រុញ ៖ មានអ្នកខ្លះគេថាដល់៣ម៉ែត្រគីប? ៣អីយ៉ាងម៉េចទៅ?

សៅរឿង ៖ អាបីម៉ែត្រគីប ។

ប្រុញ ៖ ចឹងម៉េចអាហ្នឹងខុសគ្នា?

សៅរឿង ៖ កាលលឿនគេឲ្យលើកតាមលឿន ។ ខ្ញុំមិនសូវជាទេកាលពីសម័យអាពតនោះ?

ប្រុញ ៖ អ៊ូ? ពេលដែលអឺអ្នកមិនធ្វើនៅហ្នឹង?

សៅរឿង ៖ បើយើងមិនទៅគេចាប់អូសទាញយើង ។

ប្រុញ ៖ អ៊ូ បង្ខំឲ្យយើងទៅហ្នឹង?

សៅរឿង ៖ ចា៎ស ។ បើយើងមិនណ៎ៃ ទៅធ្វើការយើងហូបបបរ គេអូយហូបបបរ ។

ប្រុញ ៖ អ្នកដែលមិនធ្វើការគេហូបបបរ? ហើយយើងអត់អាចធ្វើបានដែរម៉េចអត់អី?

សៅរឿង ៖ បើយើងតស៊ូហូបបបរទៅ ដេកនៅកន្លែងទៅ ។

ប្រុញ ៖ នៅកន្លែងហ្នឹងនៅត្រពាំងថ្នូដដែរ ប៉ុន្តែអីកម៉េច?

សៅរឿង ៖ បើយើងធ្វើពុតឈឺយើងហូបបបរទៅ សុខចិត្តហូបបបរទៅផាប់ខ្លួន ។

ប្រុញ ៖ ប្រាប់ថាៗយើងឈឺហ្នឹងគេឈឺហ្នឹងគេជឿងយើង ដែរទេអ្នកមីង? បើយើងឈឺញឹក
អីហ្នឹងគេជឿយើងដែរ?

សៅរឿង ៖ គេជឿដែល ប៉ុនតែគេតាមដានយើង ។ បើខ្ញុំមិនកើតទេ ប៉ុនតែឈឺយ៉ាងណាទៅទាំង
ឈឺ បើមិនធ្វើមិនច្រើន ច្រើនអីតិចៗ ។

ប្រុញ ៖ នៅហ្នឹងគេបែកជាកងៗឬម៉េច? ទៅធ្វើការនៅហ្នឹង?

សៅរឿង ៖ ម៉ាកងៗ ។

ប្រុញ ៖ នៅត្រពាំងថ្មូ?

សៅរឿង ៖ ម៉ាកងដប់នាក់ ។

ប្រុញ ៖ ម៉ាកង១០នាក់? មានលើសពី១០អីទៀត?

សៅរឿង ៖ ចា៎ស ។ មានក្រុមម៉ានាក់

ប្រុញ ៖ មានលើសពីដប់នាក់? មេក្រុមម៉ានាក់?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ អ៊ូ! មេក្រុមហើយក្នុងកងបែកជាក្រុម?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ ហើយម៉ាក្រុមមានដប់នាក់?

សៅរឿង ៖ ប្រធានកងធំ ។

ប្រុញ ៖ ចុះម៉ាកងមានប៉ុន្មាននាក់ទៅ? ចុះបើសរុបម៉ាកង?

សៅរឿង ៖ កងធំ?

ប្រុញ ៖ បាទ ។

សៅរឿង ៖ កងធំកងរយហ្នឹងវាម៉ាររយជាង ។

ប្រុញ ៖ មានម៉ាររយ?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ ម៉ាងកងធំមានម៉ាររយ?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ ហើយក្នុងម៉ាធំមានអីចែកជាកងតូចៗ? ទៀតទេ?

សៅរឿង ៖ ចា៎ស ចែកជាកងតូចៗ ដូចខ្ញុំប្រធានកងតូចអីចឹង ។

ប្រុញ ៖ បាទ ។

សៅរឿង ៖ ម៉ាក្រុមទៅយើងមើលកូនក្រុមយើង

ប្រុញ ៖ អ្នកមីងកាន់ម៉ាកងហើយមើលប៉ុន្មាននាក់ដែរ?

សៅរឿង ៖ ចា៎ស ។ ទំនប់សៀមរាប អត់បាន?

ប្រុញ ៖ អ៊ូ

សៅរឿង ៖ អត់បានកាន់ទេ ខ្ញុំទៅលើកត្រទ្បោកនេះម៉ាក្រុម ។

ប្រុញ ៖ ទៅលើកនោត្រទ្បោកវិញ?

សៅរឿង ៖ ទេ! បើលើកនៅអាគ្នីស្រែ កាន់នោះ កាន់ក្រុមតូច ។

ប្រុញ ៖ កាន់បានប៉ុន្មាននាក់ដែរ?

សៅរឿង ៖ ដប់នាក់ ។

ប្រុញ ៖ ១១ទាំងខ្ញុំហ្នឹង ។

សៅរឿង ៖ កាលណាក៏ទ្រាំទៅ ។

ប្រុញ ៖ ចុះពេលនោះត្រទ្បោកនិងត្រពាំងថ្មហ្នឹងពីណាធ្វើមុន?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ ពេលថា?

សៅរឿង ៖ ឯណុងមុន ។

ប្រុញ ៖ ត្រពាំងថ្មមុន?

សោវឿង ៖ ចា៎ស ។

ប្រុញ ៖ កាលពីត្រពាំងថ្មហ្នឹងអ្នកមីងស្ថិតនៅក្នុងក្រុមគេចឹង?

សោវឿង ៖ ស្ថិតនៅក្រុមគេ ។

ប្រុញ ៖ ដល់ពេលមកនេះបានមេកងគេវិញចឹងនែ៎? អូ៎ស? មេក្រុម?

សោវឿង ៖ មេក្រុម?

ប្រុញ ៖ អូ៎ស! យល់ ពាក់ព័ន្ធកន្លែងធ្វើហ្មត្រពាំងថ្មហ្នឹង?

សោវឿង ៖ មេក្រុម បើអាមេក្រុមនោះប្រជាជនថ្មីមានអី ដួលអីកាប់ដងវែកដង ។

ប្រុញ ៖ ត្រពាំងថ្មហ្នឹងគេធ្វើច្រើនទេ?

សោវឿង ៖ ត្រពាំងថ្មច្រើន ។

ប្រុញ ៖ មនុស្សធ្វើច្រើនទេ?

សោវឿង ៖ បើភូមិខុសគ្នា ។

ប្រុញ ៖ ប្រហែលជាប៉ុន្មាននាក់ទៅ?

សោវឿង ៖ នាក់ពួកចាស់ ពួកពយព្រឹងផង ដែលនៅផ្សេងគ្នាណា៎

ប្រុញ ៖ ត្រពាំងថ្មមកនេះប្រហែលជាប៉ុន្មានភូមិដែលមកហ្នឹង?

សោវឿង ៖ ចា៎សជុំគ្នាហ្នឹង, ភូមិពយព្រឹង ពយសំរោង តែនៅកងខុសកងគ្នា នៅជាមួយគ្នាហ្នឹង នៅតំបន់ប្រាំ ។

ប្រុញ ៖ អ្នកបន្ទាយមានជ័យមក? ចឹងដូចថាគេណា៎ដែលគេមកហ្នឹងគាត់ស្ថិតនៅក្រោមពីណា៎គេដឹកនាំធ្វើការនៅត្រពាំងថ្មហ្នឹង?

សោវឿង ៖ ដឹកនាំត្រពាំងថ្ម?

ប្រុញ ៖ បាទ! មេដឹកនាំ? ចុះប្រជាជនដែលមកធ្វើការហ្នឹងមកហ្នឹងសុទ្ធតែតំបន់ប្រាំទាំងមូល?

សោវឿង ៖ កាលហ្នឹងជាមួយគ្នាហ្នឹង កាលនោះមិនដឹងអ្នកណាខ្លះ បែកបាក់គ្នាអស់ ។

ប្រុញ ៖ កាលហ្នឹងមានស្គាល់ឈ្មោះអីអ្នកដែលដឹកនាំធ្វើការធ្វើអីហ្នឹង?

សោវឿង ៖ ភ្លេចអស់ហើយ បែកបាក់គ្នាអស់ សំអាតនេះ? ឈ្មោះសំអាត ។

ប្រុញ ៖ សំអាតនេះគាត់ធ្វើអីដែរ?

សោវឿង ៖ ចា៎ស?

អ្នកជិតខាង ៖ គណៈស្រុក កាលនោះធ្វើជាមួយតាបាច ។

ប្រុញ ៖ សម័យនេះមានគេឈឺស្លាប់ច្រើន?

សៅរឿង ៖ អត់ទេ អត់មានផាប់អីទេ ។

ប្រុញ ៖ អត់? ចឹងមានទេ?

សៅរឿង ៖ បើយើងធ្វើខុសគេវៃនៅត្រពាំងថ្ម បើយើងខុសគេវៃ ។

ប្រុញ ៖ ធ្វើខុស?

សៅរឿង ៖ ឈយ ម្នាក់?

ប៊ុនថន ៖ ឈយ?

សៅរឿង ៖ ចាស ម៉ានាក់នៅត្រពាំងថ្ម ។

ប្រុញ ៖ គេសម្លាប់គាត់ដោយសារអី?

សៅរឿង ៖ យើងធ្វើខុស មិនដឹងខុសអីគេ កាលនោះបើកអាគ្រាក់ប្រវត្តអាក្រក់គេវៃចោល ។

អ្នកជិតខាងៈ ប្រវត្តិគាត់ធ្វើទាហាន

ប្រុញ ៖ អ៊ូ គាត់ទាហានសម័យលន់ ណល់ ឬយ៉ាងម៉េច? ហើយគេចោទគាត់ថាម៉េចដែរ?

អ្នកជិតខាងៈ បំផ្លាញ ។

សៅរឿង ៖ ចាស ។

ប្រុញ ៖ អ៊ូ គេចោទថាយើងបំផ្លាញទ្រព្យសម្បត្តិអង្គការ?

សៅរឿង ៖ គាត់ខ្លាច ។

ប្រុញ ៖ ជាប់ប្រវត្តសម័យ លន់ នល់? ស្គាល់ពីណាគេដែលឈ្មោះ ឈយ ហើយគេវៃយក ទៅសម្លាប់

សៅរឿង ៖ ចាស ។

ប្រុញ ៖ មានស្គាល់ឈ្មោះដែលគេយកឈយហ្នឹងទៅសម្លាប់ទេ?

សៅរឿង ៖ អត់មានដឹង ។ គេយកទៅពេលវៃខ្ញុំដេកមិនដឹង គ្រាន់តែគេយកពេលយប់ភូមិតាប៉ែន ច្រើន យកតែពេលយប់ទេ ។ ខ្ញុំកាលហ្នឹងតូចអត់ដឹង យកទៅណាគេចង អត់ដឹង ។

ប្រុញ ៖ មនុស្សស្លាប់ច្រើនទេ អ្នកមីង?

សៅរឿង ៖ គ្រាន់តែរីងទទឹងនៅស្រែឯនោះ ខ្ញុំថាសុំគេខ្ញុំឈឺគេចាប់ខ្ញុំចង ដេញមក ។

ប្រុញ ៖ កាលធ្វើ?

សៅរឿង ៖ ចាប់ចងម៉ាខ្សែមិនដឹងថាប៉ុន្មាននាក់ ។

ប្រុញ ៖ កាលហ្នឹង?

សៅរឿង ៖ នៅបួនដប់នាក់មករីងទទឹងចង ។

ប្រុញ ៖ នៅពេលហ្នឹងបាយទឹកអីហូបគ្រប់គ្រាន់ទេ? ក៏យ៉ាងម៉េចដែល.?

សៅរឿង ៖ ឲ្យហូបបើធ្វើការបានហូប ។

ប្រុញ ៖ ហូបគ្រប់គ្រាន់?

សៅរឿង ៖ ចា៎ស ។ បើយើងមិនធ្វើសីងអត់ ។

ប្រុញ ៖ ចុះទឹក?

សៅរឿង ៖ ចា៎ស,

ប្រុញ ៖ ទឹកអីហូបគ្រប់គ្រាន់?

សៅរឿង ៖ ទឹកអីដងហូបខ្លួនឯង ដីកអណ្តូងហ្នឹងអ្ហែង ។

ប្រុញ ៖ ដីក?

សៅរឿង ៖ ដីកនៅនោះហ្នឹងកន្លែងធ្វើការ ។

ប្រុញ ៖ ជិតកន្លែងធ្វើការ?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ ដីកអីធម្មតាទៅ?

សៅរឿង ៖ ចា៎ស ។ ទឹកអីនាំគ្នាដងទៅ ។

ប្រុញ ៖ ទឹកមុដទឹកអីធ្លូតនៅហ្នឹងដែរ?

សៅរឿង ៖ ទឹកអណ្តូងដីក ។

ប្រុញ ៖ អោ!ហ៊ីពេលដែលមានខុទាហរណ៍ពេលមានធ្វើការអត់ហើយអីម៉េចដែរ?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ អាអីគេចែកហើយយើងធ្វើអត់ហើយ?

សៅរឿង ៖ អត់ហើយទៅ ។ ធ្វើទៀត ។

ប្រុញ ៖ គេអត់មានណែនាំយើង?

សៅរឿង ៖ គេប្រជុំ ។

ប្រុញ ៖ គេហៅយើងណែនាំ?

សៅរឿង ៖ គេប្រជុំណែនាំគេដីកហើយហេតុអីយើងមិនហើយ ។

ប្រុញ ៖ អ៊ូ!?

សៅរឿង ៖ យើងសតិអារម្មណ៍ម៉េចៗ ។

ប្រុញ ៖ ជាទូទៅគេៗគេហៅណែនាំញឹកទេ អ៊ូហៅតែម្នាក់?

សោវឿង ៖ ហៅទូទៅចាស ។

ប្រុញ ៖ ហៅទូទៅ?

សោវឿង ៖ ចាស ។

ប្រុញ ៖ ជាទូទៅណែនាំយើងពីអីវិញ?

សោវឿង ៖ ណែនាំពីរឿងគោលដៅហរ កុំផ្ញើគោលដៅហរទន់ខ្សោយ ។

ប្រុញ ៖ អ្ហ៎?

សោវឿង ៖ ហ៊ឹម! ត្រូវតែដាច់ខាតប្រឹង ។

ប្រុញ ៖ ពីណាគេដែលគេហៅយើងទៅណែនាំអីចឹង?

សោវឿង ៖ ប្រធានកងធំ ។

ប្រុញ ៖ ប្រធានកងធំ? គាត់ៗឈ្មោះអីគេ?

សោវឿង ៖ កាលណុងឈ្មោះប៉ិភិនហ្នឹងណាស ចាស ។

ឈ្មោះ ៖ ភិន? ឈ្មោះពេញអីគេ?

សោវឿង ៖ ចាស ។

ប្រុញ ៖ ឈ្មោះភិន? ចឹងហ្មង? គាត់មានឈ្មោះអីទេអ្នកមីង?

សោវឿង ៖ មិនមានទេ ។

ប្រុញ ៖ ប្រធានរបស់? ប្រធានកងធំរបស់អ្នកមីងហ្មង?

សោវឿង ៖ ហ៊ឹម ។

ប្រុញ ៖ អីគាត់ហៅប្រជុំញឹកញាប់ទេ?

សោវឿង ៖ ប្រជុំអីពីរបីថ្ងៃប្រជុំម៉ាដង ។

ប្រុញ ៖ គាត់ប្រជុំៗពីអីគេដែលអ្នកមីង?

សោវឿង ៖ ប្រជុំអារឿងការងារលើកដីហ្នឹងណា យើងប្រឹងៗទាល់តែរួច ។

ប្រុញ ៖ គាត់ប្រជុំហើយយើងប្រជុំម៉ាអាទិត្យប៉ុន្មានដង?

សោវឿង ៖ ចាស ។

ប្រុញ ៖ ហៅប្រជុំញឹកញាប់ម៉ាអាទិត្យប៉ុន្មានដង?

សោវឿង ៖ កាលម៉ាអាទិត្យប្រជុំធំម៉ាម្ដង ។

ប្រុញ ៖ ម៉ាប្រជុំធំម៉ាដង ។

សោវឿង ៖ ចាស! ម៉ាប្រជុំរាយៗបីថ្ងៃប្រជុំម៉ាដង ។

ប្រុញ ៖ ប្រជុំធំភាគច្រើនប្រជុំពីអីគេដែរ?

សៅរឿន ៖ ហា៎ស ។

ប្រុញ ៖ ប្រជុំធំ?

សៅរឿន ៖ មានប្រជុំអីប្រជុំអារឿនលើកដី ។

ប្រុញ ៖ លើកដី?

សៅរឿន ៖ ឲ្យតែយើងប្រើនឲ្យរួចលើកឥវ៉ាន់មកផ្ទះវិញ ។

ប្រុញ ៖ គាត់ៗកាចប្តុយ៉ាងម៉េចដែរឈ្មោះភិនហ្នឹង?

សៅរឿន ៖ អត់កាចទេ ។

ប្រុញ ៖ អ្នកមីងស្មានមើលមានប្រជាជនធ្វើការនៅត្រពាំងថ្មប៉ុន្មាន?

សៅរឿន ៖ ចា៎ស ។

ប្រុញ ៖ ប្រហែលៗជាប៉ុន្មាននាក់ទៅ?

សៅរឿន ៖ ចា៎ស ។

ប្រុញ ៖ ពេលធ្វើការនៅត្រពាំងថ្មហ្នឹងណា៎?

សៅរឿន ៖ ប៉ុន្មាន ។

ប្រុញ ៖ ស្មានមើលប្រហែលជាប៉ុន្មាន?

សៅរឿន ៖ រាប់ពាន់ ។

ប្រុញ ៖ រាប់ពាន់?

សៅរឿន ៖ ដល់ភូមិផ្សេងៗគ្នា? កាលណុងដូចមកចេះៗទៅរោងគេផ្សេងៗ ។

ប្រុញ ៖ បាទ! អាចដល់ម៉ឺនទេ? មនុស្ស?

សៅរឿន ៖ ពាន់ ។

ប្រុញ ៖ រាប់ពាន់?

សៅរឿន ៖ ចា៎ស ។

ប្រុញ ៖ នៅហ្នឹងគេធ្វើការស្មេៗភាពហ្នឹងអ្នកមីង?

សៅរឿន ៖ ស្មើគ្នា ។

ប្រុញ ៖ ហូបបាយហូបអីរួមគ្នាៗ?

សៅរឿន ៖ ចា៎ស ។

ប្រុញ ៖ ចុះពេលដែលគាត់ស្នាក់នៅៗឯណាវិញ?

សោរឿង ៖ ណា?

ប្រុញ ៖ អ្នកធ្វើការដែលនៅហ្នឹងទាំងអស់គ្នា?

សោរឿង ៖ នៅនោះហើយនៅរោងគេ ។

ប្រុញ ៖ នៅសម្រាករួមគ្នាចឹងហ្ន?

សោរឿង ៖ ទេ ដូចថាមេកងគាត់នៅរោងផ្សេង ដេកម៉ាខ្សែម៉ារោង

ប្រុញ ៖ មិនថាមេកងអីគាត់?

សោរឿង ៖ ចាំសគាត់ដេកជាប់ៗគ្នាហ្នឹង! ជាមួយតែគ្នា ។

ប្រុញ ៖ ហើយពេលសម្រាកហ្នឹងគេមានមកតាមដានយើងគ្នាហើយម៉េចក៏អីម៉េច?

សោរឿង ៖ ចាំស ។

ប្រុញ ៖ ពេលដែលសម្រាកពេលយប់រំខានពេលមកតាមដានយើងអីទេ?

សោរឿង ៖ អត់តាមដានទេ ។

ប្រុញ ៖ ចុះអីពេលឈឺពេលអីទៅណាវិញ? ឈឺមានពេទ្យគេណា?

សោរឿង ៖ គេមានពេទ្យអន្លង់ថ្ម ។

ប្រុញ ៖ នៅថ្ម?

សោរឿង ៖ ចាំសនៅត្រពាំងថ្ម ។

ប្រុញ ៖ ស្ពានថ្ម? អូ៎ ត្រពាំងថ្ម?

សោរឿង ៖ ចាំស ។

ប្រុញ ៖ នៅប្រចាំការនៅពេទ្យហ្នឹងហ្នងឬម៉េច?

សោរឿង ៖ ពេទ្យនៅហ្នឹង ។

ប្រុញ ៖ អ្នកដែលឈឺ?

សោរឿង ៖ ឈឺខ្លាំង ខ្ញុំកាលណុងដូចគេលើកដឹកមកដាក់ពេទ្យ ។

ប្រុញ ៖ ពេទ្យដឹកម៉េច?

សោរឿង ៖ អាអ្នកឈឺហើយគេឈឺដែល ។

ប្រុញ ៖ ពេលធ្ងន់ទៀតអីគេដឹកទៅណាទៀតអត់?

សោរឿង ៖ ពេលឈឺធ្ងន់គេដឹកមកអាណេះវិញ ។

ប្រុញ ៖ ដល់ពេលយើងជាគេឲ្យយើងទៅធ្វើការវិញ?

សោរឿង ៖ ចាំស ។

ប្រុញ ៖ ពេលដែលយើងធ្វើការអីណុងគេបង្ខំឲ្យយើងធ្វើអីឬយ៉ាងម៉េចដែរ?

សៅរឿង ៖ ទេ មានម៉ោងគេឡើងឈប់ទៅ មានម៉ោង ។

ប្រុញ ៖ មានគេឈរបញ្ជាយើងអីដែរ?

សៅរឿង ៖ គេចេះតែនៅជាប់ចឹងដែលនៅ ប៉ុន្តែយើងចេះតែធ្វើទៅយើងខ្លាចគេសម័យអាពត ។

ប្រុញ ៖ ពេលហ្នឹងមានជនជាតិវៀតណាមអីមកធ្វើច្រើន? ពួកវៀតណាម?

សៅរឿង ៖ អត់វៀតណាមទេ ខ្មែរ ។

ប្រុញ ៖ សុទ្ធតែខ្មែរទាំងអស់? ម៉េចអត់មានវៀតណាមចឹង?

សៅរឿង ៖ វៀតណាមដែលថាវាចូលរំដោះអីហ្នឹង ។

ប្រុញ ៖ ពេលធ្វើហ្នឹងអត់មានវៀតណាមទេ?

សៅរឿង ៖ អត់មានវៀតណាមទេ ។

ប្រុញ ៖ ជនចាម? ជនជាតិអីក៏អត់មានដែរ?

សៅរឿង ៖ មិនមានទេ ។

ប្រុញ ៖ សុទ្ធតែខ្មែរយើងទាំងអស?

សៅរឿង ៖ ខ្មែរយើងទាំងអស ។

ប្រុញ ៖ កាលណុងសុទ្ធតែមានប្រជាជនតាមភូមិឬមានមកពីណាដែរ?

សៅរឿង ៖ មានមកពីណា? ពី?

ប្រុញ ៖ មានមកពីភ្នំពេញអីអត់ទេ?

សៅរឿង ៖ ភ្នំពេញមាននៅតាមភូមិ ។

ប្រុញ ៖ ភ្នំពេញមកនៅហ្នឹងច្រើនទេ?

សៅរឿង ៖ ច្រើន ។

ប្រុញ ៖ ហើយពួកគាត់ស្លាប់ច្រើនទេ ។

សៅរឿង ៖ ពួកគេស្លាប់នៅឆ្ងាញ់ហើយ? ហើយយ៉ាប់ដែរ?

ប្រុញ ៖ គាត់មកនេះហូបអត់គ្រាន់ ។ ស្លាប់?

សៅរឿង ៖ ស្លាប់ដែរ ។

ប្រុញ ៖ ស្លាប់ដោយសារគាត់មានជំងឺឬក៏យ៉ាងម៉េចដែរ?

សៅរឿង ៖ ហូបមិនឆ្អែត ។

ប្រុញ ៖ ហូបអត់ឆ្អែតធ្វើការធ្ងន់?

សៅរឿង ៖ ធ្វើការធ្ងន់អី គេឲ្យយើងកាប់ព្រៃកាប់អីហើយលើកទំនប់ក៏ដូចជាធ្ងន់ហើយហូបមិនឆ្អែត ហើយមិនមានកម្លាំងឈឺ ។

ប្រុញ ៖ ពេលធ្វើការនៅហ្នឹងមានគេចុះមកមើលញឹកញាប់ទេ? មានអ្នកធំចុះៗមកមើលញឹកញាប់ៗទេ?

សៅរឿង ៖ អ្នកធំមកម៉ាម្តងៗ ។

ប្រុញ ៖ អ្នកណាគេ?

សៅរឿង ៖ ចាស! ខ្ញុំអត់ដឹងដែល ។

ប្រុញ ៖ ប៉ុន្តែស្គាល់ថាមានគេមក?

សៅរឿង ៖ មានគេធំ ។

ប្រុញ ៖ ភាគច្រើនគណៈស្រុកអីគណៈតំបន់.? គេចុះមកមើល?

សៅរឿង ៖ ចាស ។ គណៈតំបន់ ។

ប្រុញ ៖ គណៈតំបន់អី? មានគណៈភូមិភាគអីមកទេ?

សៅរឿង ៖ មិនមានទេ ។

ប្រុញ ៖ គណៈតំបន់ឈ្មោះអីគេ?

សៅរឿង ៖ មិនដែលស្គាល់ផង ។

ប្រុញ ៖ អត់ស្គាល់ ។

សៅរឿង ៖ អត់ស្គាល់ ។

ប្រុញ ៖ អ្នកមីងអីមានស្គាល់ឈ្មោះ រ៉ាល់?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ រ៉ាល់?

សៅរឿង ៖ តារ៉ាល់នៅទំនប់រនុះបាញ់ ។

ប្រុញ ៖ ចុះទំនប់? តារ៉ាល់ហ្នឹងគាត់នៅខាងអីគេវិញ?

សៅរឿង ៖ ចាស ។ យោធា ។

ប្រុញ ៖ ដែលជួបមុខតារ៉ាល់ហ្នឹងដែលអត់ទេ?

សៅរឿង ៖ អត់ដែលទេ ។ វល់វេះវៃចោល ។

ប្រុញ ៖ ពេលធ្វើនៅហ្នឹងខែឆ្នាំណាដែរ?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ ធ្វើនៅត្រពាំងថ្ម?

សៅរឿង ៖ ចាំសមិនចាំទេ ។

ប្រុញ ៖ ប៉ុន្តែធ្វើនៅហ្នឹងបានយូរទេ?

សៅរឿង ៖ វាមិនបានយូរប៉ុន្មានទេ ។

ប្រុញ ៖ អត់បានយូរ?

សៅរឿង ៖ ធ្វើមិនបានយូរ កាលហ្នឹងខ្ញុំធ្វើអត់បានយូរ ។ ខ្មែមកដេកពេទ្យភូមិគេក្រោយហ្នឹង ។

ប្រុញ ៖ កាលណុងអ្នកមីងឈឺអីគេ?

សៅរឿង ៖ ខ្ញុំកាលណុងស្គមឡើង ។

ប្រុញ ៖ ធ្វើការហត់ពេកហ៊ី?

សៅរឿង ៖ មានរោគខ្លួនឯង រោគធ្លាក់ស ក៏ស្គម ។

ប្រុញ ៖ បាទ! កាលណុងឲ្យយើងធ្វើការដែរកាលណុងយើងឈឺចឹង?

សៅរឿង ៖ ហ៊ឺ!កាលណោះគេមិនជឿយើង ។

ប្រុញ ៖ អត់ជឿយើង?

សៅរឿង ៖ ចេះតែដេញយើងទៅ យើងមិនថាដែលខ្ញុំមិនទៅគេចាប់ចង ។

ប្រុញ ៖ បាទ ។

សៅរឿង ៖ ខ្ញុំសុំទេ តែគេមិនសុខចិត្តទៅហើយបានប៉ុន្មានថ្ងៃខ្ញុំមកវិញ បានម៉ាខែពីរខែ ។

ប្រុញ ៖ ចឹងអ្នកមីងធ្វើការនៅឯត្រពាំងថ្មហ្នឹងបានតែពីរបីខែទេ?

សៅរឿង ៖ ចាស ។

ប្រុញ ៖ ហើយឈឺចឹងទៅ?

សៅរឿង ៖ ចាំស គេយកមកដាក់ពេទ្យ ទៅពេទ្យស្វាយមិនជា មកស្រុកវិញ ។

ប៊ុនថន ៖ ជាត្រឹមស្រុកហ្នឹង?

សៅរឿង ៖ មកស្រុកវិញយកថ្នាំខ្មែរផឹក គ្រាន់បាត់ ។

ប្រុញ ៖ អូ៎! ហើយដល់ពេលក្រោយពីហ្នឹងមក គេឲ្យអ្នកមីងទៅណាទៀតទៅ?

សៅរឿង ៖ ចាំស នៅក្នុងស្រុកនេះ ខ្ញុំនៅត្រឹមស្រុកនេះនៅដាំបាយកន្លែងនេះ គេនៅក្រៅភូមិ គេអ្នកដកសំណាបដកអី?

ប្រុញ ៖ បាទ! ។

សៅរឿង ៖ ប្រជាជនគេដកសំណាបហើយខ្ញុំនៅដាំបាយខាងចុងភៅ ។

ប្រុញ ៖ ដាំ? ធ្វើខាងចុងភៅវិញ?

សៅរឿង ៖ ចាស ។

ប្រុញ ៖ ចុះអឺពេលណាដែលអ្នកមីងបានទៅធ្វើការអឺនៅទំនប់ត្រឡោកនោះ?

សៅរឿង ៖ ទំនប់ត្រឡោក? អឺហ្នឹងណ៎?

ប្រុញ ៖ បាទ!

សៅរឿង ៖ កាលណុងពេលដែលខ្ញុំមកពីស្វាយ គេឲ្យទៅទំនប់ត្រឡោក ។

ប្រុញ ៖ ចុះពេលអឺដាំបាយឲ្យគេហើយហ្នឹងនៅទំនប់ត្រឡោកនោះពីណាធ្វើមុន?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ ធ្វើនៅណាមុន?

សៅរឿង ៖ ធ្វើនៅត្រឡោកមុន ។

ប្រុញ ៖ ធ្វើត្រឡោកមុន?

សៅរឿង ៖ ចា៎ស ។

ប្រុញ ៖ ធ្វើត្រឡោកហ្នឹងបានប្រហែលជាប៉ុន្មានខែដែរ?

សៅរឿង ៖ ចា៎ស នៅពេលប្រហែលជាពីរខែ លើកអាប្រព័ន្ធភ្លឺស្រែ ។

ប្រុញ ៖ លើកភ្លឺស្រែ? ដល់ពេលបានពីរខែហើយទើប?

សៅរឿង ៖ នាំគ្នាដលកសំណាប ។ ខ្ញុំនៅធ្វើចុងភៅ ។

ប្រុញ ៖ បាទ ។

សៅរឿង ៖ ចុងភៅគេឲ្យគ្នាដកសំណាបដកអី? ស្ទូងអីណ៎ភូមិតាប៉ែន ។

ប្រុញ ៖ ភាគច្រើនខាងពីណាវិញ?

សៅរឿង ៖ ភូមិហ្នឹងពាយព្រីងហ្នឹងអែងស្រុកពាយព្រីង ។

ប្រុញ ៖ ស្រុកពាយព្រីង?

សៅរឿង ៖ អ្អែងនេះទៅនៅទៅដក ។

ប្រុញ ៖ នៅហ្នឹងគេដកសំណាបតែម្តងឬម៉េចដែរ?

សៅរឿង ៖ ដកសំណាបស្ទូង ។

ប្រុញ ៖ បាទ! គេគ្រាន់តែសំណាប ។

សៅរឿង ៖ ចា៎ស! ដកស្ទូង។

ប្រុញ ៖ នៅហ្នឹងគ្នាច្រើននាក់ទេ?

សៅរឿង ៖ ស្រែច្រើន ។

ប្រុញ ៖ ចុះអីក្រោយពីទំនប់ត្រពាំងថ្មហ្នឹងក្រោយពីហ្នឹងតើមីងមានដឹងអីទៀតទេ?

សៅរឿង ៖ អត់ដឹងទេ ។

ប្រុញ ៖ អត់ដឹងថាគេធ្វើទំនប់ហ្នឹងហើយនៅពេលណាអីទេ?

សៅរឿង ៖ អត់ដឹងខ្ញុំមកមុន ខ្ញុំឡើមកផ្ទះ ទេ អង្គការម៉ែអ្នែង សម័យអាពត?

ប្រុញ ៖ ពេលដល់ពេលដាំបាយអីទៀតទៅ?

សៅរឿង ៖ ដាំបាយទៅ គេប្រូតស្រូវវាលនោះ?

ប្រុញ ៖ ទៅប្រូតស្រូវវិញ?

សៅរឿង ៖ ចាស ។

ប្រុញ ៖ ទៅប្រូតស្រូវពីណាគេធ្វើមេកង? ហ៊ីមីង?

សៅរឿង ៖ ប្រូតៗកាលណុងប្រូតយកខ្លួនឯង ។

ប្រុញ ៖ យកខ្លួនឯង?

សៅរឿង ៖ ចាស ។

ប្រុញ ៖ កាលណុងហ្នឹងមានគេចែងដាកងណាដូចនៅទំនប់ ត្រពាំងថ្មកាលនៅទំនប់ ត្រឡោក ហ្នឹងដែរ?

សៅរឿង ៖ ពេលប្រូតហ្នឹង?

ប្រុញ ៖ មានទេ?

សៅរឿង ៖ កាលហ្នឹងគេមានឈ្មោះសាមគ្គី ។

ប្រុញ ៖ សាមគ្គីហ្នឹងប៉ុន្តែស្ថិតនៅសម័យខ្មែរក្រហមដដែរ ។

សៅរឿង ៖ ផុតហើយផុតអស់ហើយ ។

ប្រុញ ៖ ចឹង?

សៅរឿង ៖ ស៊ីមិនឆ្អែតយ៉ាប់ ។

ប្រុញ ៖ សម័យហ្នឹងមានគេលួចដំឡូងលួចអីដែរ?

សៅរឿង ៖ លួច! ប៉ុន្តែខ្ញុំមិនលួច ។

ប្រុញ ៖ ដែលគេចាប់ទាន់?

សៅរឿង ៖ ទេដែលលួចឲ្យទាន់ទេ ។

ប្រុញ ៖ ចឹងបើសិនជាគេទាន់គេធ្វើម៉េចទៅ?

សៅរឿង ៖ គេវៃចាប់ចង ។

ប្រុញ ៖ ដែលគេយកទៅសម្លាប់អីទេត?

សៅរឿង ៖ ចាស ដែលលួចអីចឹងគេយកទៅសម្លាប់ទេ យើងមិនទាហាន ។

ប្រុញ ៖ តែទាហានគេយកទៅសម្លាប់?

សៅរឿង ៖ ចាស ។

ប្រុញ ៖ មីងធ្លាប់ឃើញដែលគេសម្លាប់ទាហាន?

សៅរឿង ៖ ចាស ។

ប្រុញ ៖ ធ្លាប់ឃើញគេសម្លាប់ទាហាន? ធ្លាប់ឃើញ?

សៅរឿង ៖ មិនដែលឃើញ ។

ប្រុញ ៖ អត់ដែលឃើញ?

សៅរឿង ៖ ចាស! គេដែលឲ្យយើងសូវឃើញហ្នឹងណា គេយកទៅស្ងាត់ៗ ។

អ្នកជិតខាង ៖ គេយកទៅសម្លាប់ឈ្មោះ ស ឈ្មោះ មឿក

ប្រុញ ៖ គាត់ហ្នឹងឈ្មោះអីគេដែល? ឈ្មោះ ស ឈ្មោះ មឿក? អ្នកណាគេដែល យកទៅសម្លាប់?

អ្នកជិតខាង ៖ ខ្មែរក្រហមហ្នឹង ។

ប្រុញ ៖ អត់ស្គាល់ឈ្មោះ?

សៅរឿង ៖ មិនដែលស្គាល់ឈ្មោះក៏រកវាមិនឃើញ ។

ប្រុញ ៖ នៅហ្នឹងទាហានសម័យលន់នល់ប្តូយ៉ាងម៉េច? គេដឹងថាទាហានសម័យលន់នល់ទេ?

សៅរឿង ៖ ដឹងដូចអូនអ្អែងនេះប្រាប់ហើយចុចប្រាប់ ហើយកុំឲ្យនិយាយអ្វីទាំងអស់ បើចោះហើយរស់ហើយមិនត្រូវគ្នា ។

ប្រុញ ៖ បាទ!

សៅរឿង ៖ ចោទនេះសុទ្ធតាទាហាន ។

ប្រុញ ៖ យើងនិយាយថាពាក្យធ្វើទាហាននេះតាំងពីសង្គមចាស់មក?

សៅរឿង ៖ តាំងពីសង្គមចាស់មក ហ្នឹងហើយធ្វើទាហានដល់ពេលយើងនិយាយទៅចាប់យើងបាន

ប្រុញ ៖ បាទ!

សៅរឿង ៖ យ៉ាប់ណាស់យកល្អរៀងខ្លួនប្រាប់គេមិនអីប៉ុន្តែមានសាប់អែងៗ ។

ប្រុញ ៖ ចុះអ្នកផ្សេងៗធ្វើការសម័យលន់លន់ហ្នឹងគេសម្លាប់ដែរម៉េចដែរ?

សោរឿង ៖ ទេ! ឲ្យតែនិយាយប្រាប់ទាហានដឹងតែស្លាប់ ។

ប៊ុញ ៖ ឲ្យតែទាហានដឹងតែគេសម្លាប់ចោលហើយ?

សោរឿង ៖ ចា៎ស! គេចាប់យក ចាប់ទៅគេមិនឲ្យយើងដឹងណា គេឈ្លបចាប់ នេះប្អូនខ្ញុំនៅផ្ទះហ្នឹង វានៅតូចហើយបបរមួយវែកបានកាកមួយស្លាបព្រា ខ្ញុំស៊ីដើមចេកអីចេះ កាប់ស្ងោរ កាប់ស្ងោរៗផង ស្ងោត្រកួនដាំបាយហើយអង្ករម៉ាកំប៉ុងដាក់វាយ ។

ប៊ុញ ៖ ហូបបបរ?

សោរឿង ៖ ហូបបបរហូបអី ។

ប៊ុញ ៖ កំពុងធ្វើការដ្ឋាននៅត្រពាំងថ្មហ្នឹងយ៉ាងម៉េចដែរ?

សោរឿង ៖ ត្រពាំងថ្មហ្នឹងបើយើងធ្វើការពីទំនប់បានបាយ ។

ប៊ុញ ៖ បើយធ្វើការនៅទំនប់បានបាយ?

សោរឿង ៖ មិនទេ បបររួមដែរនៅផ្ទះអី មិននៅដឹងភូមិគាត់នៅឯណា បើខ្ញុំមិននៅអី គាត់នៅតាមកងបើខ្ញុំនៅទៅដឹកសំណាបទៅ ខ្ញុំក៏បបរឆ្នាំងខ្ទះឲ្យគេ បបរមិននេះទេ បើធ្វើការបបរខាប់ៗឲ្យ ។

ប៊ុញ ៖ បាទ! ចុះមានដឹងថាមានគេសម្លាប់ជនជាតិពួកវៀតណាមពួកអីទេ?

សោរឿង ៖ ទេ វៀតណាមមិនបានសម្លាប់ទេ ។

ប៊ុញ ៖ អត់បានសម្លាប់ ។ នៅហ្នឹងអត់មាន?

សោរឿង ៖ មានតែខ្មែរយើង ។

ប៊ុញ ៖ សម្លាប់តែខ្មែរយើង?

សោរឿង ៖ ខ្មែរយើងច្រើនហ្មង់ ប្អូនខ្ញុំស្លាប់ម៉ានាក់ស្លាប់នៅផ្ទះហ្នឹង ។ កាលវៀតណាមវាមក បាញ់ខ្មែរក្រហមបាញ់វៀតណាម ។ វៀតណាមមកតាមនេះ ។

ប៊ុញ ៖ ឈ្មោះអីគេដែរអ្នកមីង? ប្អូនបង្កើត?

សោរឿង ៖ ប្អូនបង្កើត ។

ប៊ុញ ៖ គាត់ឈ្មោះអីគេអ្នកមីង?

សោរឿង ៖ គ្រុំ ។

ប៊ុញ ៖ ឈ្មោះគ្រុំ?

សោរឿង ៖ ចាស ។ កាលបាញ់ត្រូវក្បាល ។

ប៊ុញ ៖ គាត់ពេលហ្នឹង ហើយពេលណាដែលបាញ់ត្រូវគាត់?

សៅរឿន ៖ ចាស ។ ដែលវៀតណាមទៅលេង កាលវៀតណាមចូលហើយ ។

ប្រុញ ៖ វៀតណាមចូលហើយ?

សៅរឿន ៖ ចាស ។ បាញ់រួច ។

ប្រុញ ៖ អូ! ពេលហ្នឹងខ្មែរក្រហមបែកចេញពីភូមិវិញ?

សៅរឿន ៖ វាបែក ។

ប្រុញ ៖ ខាងវៀតណាមចូលបែកហើយ?

សៅរឿន ៖ ចូលហើយ ចូលនៅតាមវត្ត ដល់នេះវាដេញតាមវៀតណាមមក ត្រូវអាប្អូនខ្ញុំ ត្រូវក្បាល ។

ប្រុញ ៖ អូ! ចឹងអ្នកបាញ់ត្រូវខ្មែរក្រហមអ្នកបាញ់?

សៅរឿន ៖ អ្នកបាញ់?

ប្រុញ ៖ ប៉ុន្តែបាញ់ហើយអាឆាហានវៀតណាម?

សៅរឿន ៖ ចាស ។ ហើយស្រួលហើយវៀតណាមចូលមក ដល់ពេលវៀតណាមសម្រុកមក គេថាវៀតណាមអីណែ៎ នៅវត្ត វៀតណាមវាមកចុះអែង វារត់តាមផ្លូវ ប្អូនខ្ញុំវាងាប់នៅអាគាណេះហ្នឹងអែង វៀតណាមសម្រុកចូលមក ។

ប្រុញ ៖ ជំនាន់ហ្នឹងស្គាល់អ្នកធំអីសម័យហ្នឹង?

សៅរឿន ៖ មិនស្គាល់ទេ ។

ប្រុញ ៖ អត់មានពីណាគាត់ហៅឈ្មោះធ្លាប់ឈ្មោះអី? ធ្វើការ?

សៅរឿន ៖ សុទ្ធតែលួចលាក់ ដាក់អង្កាម ហើយវិចអង្កាម អង្ករដាក់ក្រោម សម័យអាពតយ៉ាប់ណាស់ បើហ៊ានលួចបានរស់ ។ ខ្លះទៅបូតស្រូវដាក់លីងហើយបុកៗក៏អឹមអង្ករ មិនអីបើប៉ុណ្ណោះមិនរស់ងាប់អស់ហើយ ។ ខ្ញុំស្រោបស្លឹកចេក ។

ប្រុញ ៖ មីងអាចនិយាយថាសង្ខេបថាធ្វើការហ្នឹងមីងហត់នឿយអីខ្លះដាងគេ? លំបាកអីខ្លះ
ហើយនិយាយ?

សៅរឿន ៖ មិនបានឈប់ទេ សម័យអាពតវាមិនឲ្យស៊ី សម័យអាពតហ្នឹងធ្វើស្រូវបានច្រើនមិនដឹងថាយកទៅឯណាអស់ ប្រូតបានដឹកបាន មិនដឹងយកទៅណាអស់ ដឹកចូលជង្រុក ប៉ុនឲ្យស៊ីបបរ ពួកគេឯណោះដឹកតែបាវ ហើយយ៉ាប់តែតំបន់ប្រាំ តំបន់នេះស៊ីតែបបរមិនឆ្អែត ។

ប្រុញ ៖ តំបន់នេះធ្វើការហត់ជាងគេអី?

សោរឿង ៖ គាស់ឫស គាស់អី ចេះតែធ្វើការ ឲ្យតែគេឲ្យស៊ី បើយើងមិនកើតគេអត់ ។

ប្រុញ ៖ ពេលយើងឈឺអីគេមើលយើងត្រឹមត្រូវ?

សោរឿង ៖ ហ៊ឹម ៗ មិនមានអ្នកណាគេមើល ដឹកថ្នាំខ្មែរអីខ្លួនទៅ ។ ពេទ្យ ៗ គេឲ្យថ្នាំប្រហែល តែមនុស្សចេះតែរស់ ខ្ញុំថាមិនរស់ផង ស្លុមឡើងខាំប្រើង ប្អូនខ្ញុំឃ្លានអាវី បងអើយ ស្ងោគ្តិបចេកទៅ កាប់គាស់ស្ងោរឲ្យទៅ ចេះតែកន្ទេងផ្ទះនៅដាំអំពៅដាំអី ហើយចិញ្ចឹមមាន់មិនហ៊ានស៊ីមិនហ៊ានអី លួចសុទ្ធតែលួចលាក់ ហើយដាំបាយលួចលាក់ ។

ប្រុញ ៖ បើសិនជាគេទាន់? គេធ្វើអីយើងទេ?

សោរឿង ៖ ទាន់សល់តែឆ្អឹង គេវៃ ទាល់តែលួចលាក់ ខ្ញុំបានអង្ករនេះអាជញ្ជាំងផ្ទះ ដាក់លាក់ជាងពីរជញ្ជាំងដាក់លាក់ ។ ខ្វះទៅជំឡូងមីគេជិះកប់តាមផ្ទះ ។

ប្រុញ ៖ បាទ ។

សោរឿង ៖ ទៅលួចយប់ឡើងលួចចេញទៅ លួចលាក់ ។

ប្រុញ ៖ ហើយបងប្អូនអ្នកមីងជំនាន់ហ្នឹងអត់មានបាត់បង់អីណា៎? រស់ទាំងអស់គ្នា?

សោរឿង ៖ រស់ទាំងអស់គ្នា ។ កាលទឹមចូលសម័យវៀតណាមនេះ ទើបងាប់ ។

ប្រុញ ៖ វៀតណាមចូលមកទើបគាត់ស្លាប់វិញ ។

សោរឿង ៖ បាញ់ស្រេចចូលមក ។

ប្រុញ ៖ បាទ! បងប្អូនអ្នកមីងប៉ុន្មាននាក់ដែរ?

សោរឿង ៖ ប្រាំមួយនាក់ ។

ប្រុញ ៖ ប្រុសប៉ុន្មាន? ហើយស្រីប៉ុន្មាន?

សោរឿង ៖ ប្រុសបីស្រីបី ។

ប្រុញ ៖ អូ៎! ស្មើគ្នាល្អណាស់ ។

សោរឿង ៖ ហ៊ឹម!

ប្រុញ ៖ ហើយអ្នកមីងត្រូវជាបងគេបង្អស់?

សោរឿង ៖ បងគេបង្អស់ ។

ប្រុញ ៖ ប្អូនមីង ៗ កាលគេជំនាន់ហ្នឹងមានអាយុប៉ុន្មាន?

សោរឿង ៖ អេ៎ កាលនោះកាន់អី វាញូវស្រែ ។

ប្រុញ ៖ អូ៎ គាត់ធំ? ក្មេរ?

សោរឿង ៖ ពុកខ្ញុំ ចាស! តូចតែមួយនេះពៅគេ នៅផ្ទះបានបងប្រុសម៉ាស្លាបព្រោះ ។
ប្រុញ ៖ ឪពុកអ្នកមីងអីគាត់ដែរអី?
សោរឿង ៖ ងាប់អស់ហើយ ។
ប្រុញ ៖ គាត់ៗ?
សោរឿង ៖ សម័យអាពត ។
ប្រុញ ៖ អ៊ូ សម័យអាពត? គាត់ៗស្លាប់ដោយសារអីគេ?
សោរឿង ៖ ឪពុកខ្ញុំគាត់ដើរទៅស្រុកក្រោមហ្នឹង គាត់ថាដើរទៅស្រុកគាត់នៅឯណុង ហើយបពន្ធនៅស្រុកនេះ គាត់ៗនៅសំបួរ ។
ប្រុញ ៖ ហេតុអ្វីបានគេសម្លាប់គាត់?
សោរឿង ៖ មិនស្លាប់ទេ គាត់ឈឺដើរទៅតែម្ដង ។
ប្រុញ ៖ ចុះៗ?
សោរឿង ៖ ម៉ែខ្ញុំងាប់សម្លាប់អាពត ។
ប្រុញ ៖ គាត់ជំងឺដែរឬក៏យ៉ាងម៉េចដែរ?
សោរឿង ៖ ជំងឺ ។
ប្រុញ ៖ ប៉ុន្តែគាត់ធ្វើការនៅហ្នឹងដែរឬក៏អត់ទេ?
សោរឿង ៖ ចាស ។
ប្រុញ ៖ គាត់ធ្វើការនៅហ្នឹងដែរអត់ទេ?
សោរឿង ៖ នៅធ្វើ គាត់ជានៅ ប៉ុនតែគាត់ឈឺទៅយកមកដេកពេទ្យ កាលលើកមុនពេទ្យក្នុងវត្ត ។
ប្រុញ ៖ ធ្វើនៅត្រពាំងថ្មហ្នឹងអី?
សោរឿង ៖ ទេអត់ទេ ។ គាត់ងាប់ ។ សម័យអាពតងាប់អស់ ខ្ញុំកូនកំព្រាទេ
ប្រុញ ៖ អាយុប៉ុន្មាន២៥ជាង?
សោរឿង ៖ ២៥ជាង ។
ប្រុញ ៖ អស់សំនួរហើយ?
សោរឿង ៖ មានអីសួរទៀត ។
ប្រុញ ៖ មីងមានអីចង់បន្ថែមអីទៀតអត់?
សោរឿង ៖ មិនដឹងសួរអី?
ប្រុញ ៖ អីឥលូវគេមានអី តុលាការទោសមេដឹកនាំខ្ពស់បំផុតនៅសម័យខ្មែរក្រហម ។

សោវឿង ៖ ចាស ។

ប្រុញ ៖ គេអត់កាត់អីអ្នកតូចតាមកងតាមអីទេ គេកាត់តែមេធំៗអីហ្នឹង ។

សោវឿង ៖ ចាស ។

ប្រុញ ៖ គេកាត់មេធំ មាន , អៀង សារី , ខៀវ សំផន, អៀង ធីរិទ្ធ, នួន ជា,។ ប៉ុន្តែនៅបួននាក់គេកាត់ ។ ហើយនៅនេះគេមានដែលផ្សាយព័ត៌មានអីអត?

សោវឿង ៖ អត់ផ្សាយដែរ ។

ប្រុញ ៖ អត់ដែលផ្សាយទេ? រួចមានចាក់តាមទូរទស្សន៍? ព័ត៌មាន?

សោវឿង ៖ ស្តាប់ ហើយឡែទៅមើល មិនដែលស្តាប់ ។

ប្រុញ ៖ អ្នកមីងយល់ម៉េចដែរពេលដែលតុលាការកាត់ទោសមេដឹកនាំខ្ពស់ ប្រជាជនម៉េចដែរ?

សោវឿង ៖ ហ៊ឹម! ឈឺចាប់គឺឈឺចាប់ហើយមិនដឹងថាធ្វើម៉េច, ។

ប្រុញ ៖ ចឹងអត់ទេ ហើយអរគុណច្រើនអ្នកមីង!

សោវឿង ៖ ចា៎ស ។

ប្រុញ ៖ ហើយអស់អីសួរអ្នកមីងហើយ ។

សោវឿង ៖ សំណាងល្អណា៎ ។

ប្រុញ ៖ បាទ!

«ចប់»